**Declassified to Public**
**28 October 2021**



**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់** | : | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2016, 14:51
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា**
**ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១**
**និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញាអន្តរជាតិ:
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

ការិ.សហចៅក្រមស៊ើបអង្កេត:
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Siegfried BLUNK

**ចម្លងជូន:**

សហព្រះរាជអាជ្ញាជាតិ:
លោកស្រី ជា លាង

## ១. សេចក្តីផ្តើម

១. ជាបន្តពីដីកាសំរេចលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត (“សចស” ឬ “កសចស”) កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ (“ដីកាសម្រេច”)[1] សហព្រះរាជអាជ្ញាអន្តរជាតិ (“ICP”) សូមដាក់ជូនមកនេះនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[2] ជាលើកទីពីរ ក្នុងទម្រង់ដូចមុនបេះបិទ ហើយសូមស្នើឲ្យ កសចស មេត្តាពិនិត្យពិចារណាលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះទៅលើអង្គសេចក្តី។

២. ពីដំបូង តាមដីកាចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ សចស បានតម្រូវឲ្យសហព្រះរាជអាជ្ញាបង្ហាញឲ្យបានដឹងថា តើការខ្វែងយោបល់គ្នាមានត្រូវបានចុះក្នុងកំណត់ហេតុអនុលោមតាមវិធាន ៧១.១ នៃវិធានផ្ទៃក្នុង ដែរឬទេ? ថ្វីបើមានការយោងដោយច្បាស់ៗទៅលើការខ្វែងយោបល់គ្នានោះនៅក្នុងអត្ថបទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដោយផ្ទាល់ក៏ដោយ[3]។ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានបញ្ជាក់ជូនហើយថា ការខ្វែងយោបល់គ្នានោះគឺត្រូវបានចុះនៅក្នុងកំណត់ហេតុនៅមុនការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពិតប្រាកដ[4]។

៣. ក្រោយមកទៀត តាមរយៈដីកាសម្រេចចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ សចស បានសម្រេចថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះគ្មានសុពលភាពទេ ដោយសាររយៈពេល ៣០ថ្ងៃ នៃការដោះស្រាយការខ្វែងយោបល់គ្នាដែលបានកំណត់អាណត្តិដោយវិធាន ៧១.៣ នៃវិធានផ្ទៃក្នុង មិនទាន់ត្រូវបានផុតកំណត់នៅឡើយទេ[5] ។ ចំពោះមូលហេតុដូចដែលមាននៅក្នុងកថាខណ្ឌទី២៥ ខាងក្រោមនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមដាក់ជូននៅទីនេះ នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ជាទម្រង់ដើមរបស់វា ហើយនិងសូមស្នើដល់ សចស សូមឲ្យចាត់វិធានការធ្វើការស៊ើបសួរដូចដែលបានរៀបរាប់នៅក្នុងនោះ ជាបន្ទាន់ ។

---

[1] ដីកាសម្រេចលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ចុះថ្ងៃទី៣០ មិថុនា ២០១១, ឯកសារលេខ D27/3, ERN 00710771-73។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ចុះថ្ងៃទី១៥ មិថុនា ២០១១, ឯកសារលេខ D27, ERN 00706357-67។

[3] *ដូចគ្នានឹងខាងលើ* , កថាខណ្ឌទី២២។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាសម្រេចចុះថ្ងៃទី១៧ មិថុនា ២០១១ របស់សហចៅក្រមស៊ើបអង្កេត ស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, ចុះថ្ងៃទី២១ មិថុនា ២០១១, ឯកសារលេខ D27/2 , ERN 00710791-92។

[5] ដីកាសំរេច កំណត់សំគាល់លេខ១*ខាងលើ*, ត្រង់កថាខណ្ឌទី៤-៥។

៤. ដោយអនុលោមតាមវិធាន ៥៣ និង ៥៥ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាសូមដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ ដែលសហព្រះរាជអាជ្ញាមានគោលបំណងដាក់បន្ថែម និងបញ្ជាក់អំពីបញ្ហាអង្គហេតុនានា ដែលនឹងត្រូវធ្វើការស៊ើបអង្កេតដោយ សហចៅក្រមស៊ើបអង្កេត ("សចស" ឬ "កសចស") នៅក្នុងសំណុំរឿងលេខ ០០៤ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ បានបន្ថែមទីតាំងឧក្រិដ្ឋកម្មថ្មីផ្សេងៗនៅតំបន់១ ក្នុងភូមិភាគពាយ័ព្យ និងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តទៅលើពួកខ្មែរក្រោមនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ, ព្រមទាំងបញ្ជាក់ និងបន្ថែមនូវឧក្រិដ្ឋកម្មនានា ដែលត្រូវស៊ើបអង្កេតពីមុនៗ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី៧៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣, ដោយមានមូលដ្ឋានបឋមនៅលើពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី, បណ្តឹង និងបទសម្ភាសន៍នានាដែលត្រូវបានទទួល ឬត្រូវបានជូនដំណឹងនៅក្នុងសំណុំរឿងលេខ០០២ បន្ទាប់ពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ។ ឧក្រិដ្ឋកម្មទាំងនោះមានរៀបរាប់នៅខាងក្រោម ត្រង់កថាខណ្ឌទី ៥ ដល់ ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ និងត្រូវបានគេជឿថាស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក ។ សហព្រះរាជអាជ្ញា ស្នើថា ឧក្រិដ្ឋកម្មទាំងនេះគឺក្លាយទៅជាផ្នែកមួយនៃសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស, ដែល សចស កំពុងធ្វើការស៊ើបសួរ ។

## ២. អំពីឧក្រិដ្ឋកម្ម

### *ស្រុកគាស់ក្រឡ - មន្ទីរសន្តិសុខធិបតី និង ការដ្ឋានទួលម្ទេស*

៥. មន្ទីរសន្តិសុខធិបតី និងការដ្ឋានទួលម្ទេស មានទីតាំងនៅឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលជាផ្នែកមួយនៃតំបន់១ ក្នុងភូមិភាគពាយ័ព្យ ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[6] ។ មន្ទីរសន្តិសុខនេះ ត្រូវបានគេយោងដោយមានឈ្មោះផ្សេងៗពីគ្នា រួមមាន មន្ទីរសន្តិសុខវត្តធិបតី[7],

---

[6] របាយការណ៍ DC-Cam ក្រោមចំណងជើងថា *ការធ្វើផែនទីស្តីពីវាលពិឃាតនៅកម្ពុជា, ឆ្នាំ១៩៩៧៖ ខេត្តបាត់ដំបង,* D1.3.27.7 ត្រង់លេខ ERN 00078166 [ដោយបានកំណត់អត្តសញ្ញាណថា "ភ្នំធិបតី" ជា "មន្ទីរសន្តិសុខធំ និងជាគុក" នៅក្នុងស្រុកមោងឫស្សី ប៉ុន្តែមិនអាចធ្វើដំណើរទៅទីនោះបានទេដោយសារហេតុផលសន្តិសុខ] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កឺ សឹង (KEU Seung), D22/2139/1 ត្រង់លេខ ERN 00546061 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កឹម ផេង (KOEM Pheng), D22/2141/1 ត្រង់លេខ ERN 00546087-88 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ទី (CHEA Chanty), D22/3106/1 ត្រង់លេខ ERN 00561505-06 ។ បណ្តឹងរបស់ អាវ សុខចំរើន (AV Sok Chamroeun), D230/2/4.2.68b ត្រង់លេខ ERN 00503074។ បទសម្ភាសន៍របស់ កសព លើឈ្មោះ នួន មួន (NOUN Moun),D1.3.11.36 ត្រង់លេខERN 00210532។ បណ្តឹងរបស់ រឿង សុភាព (ROEUNG Sopheap), D230/1.1.671c ត្រង់លេខ ERN 00477557 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហង់ បុរី (HANG Borey), D22/3882/1 ត្រង់លេខ ERN 00571582 ។ សេចក្តីសង្ខេបព័ត៌មានបន្ថែមរបស់ កៅ ផារី (KAO Phary), D22/3221b ត្រង់លេខ ERN 00587278 [អ្នកដាក់ពាក្យបណ្តឹង "ត្រូវបានបង្ខំឲ្យកសាងទំនប់នៅភ្នំធិបតី"] ។ របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពីតំបន់១, ថ្ងៃទី២៨ ឧសភា ១៩៧៧, D1.3.10.2 ត្រង់លេខ ERN 00143567-68 [ពិភាក្សាអំពីស្រុកគាស់ក្រឡ និង ការដ្ឋាន "អាងទឹកធិបតី" ថាជាផ្នែកនៃតំបន់១] ។

[7] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ទី (CHEA Chanty), D22/3106/1 ត្រង់លេខ ERN 00561505 ។

គុកភ្នំធិបតី[8] និង មន្ទីរសន្តិសុខគាស់ក្រឡ[9] ។ ពួកអ្នកជាប់ឃុំនៅក្នុងគុកនេះ រួមមាន ជនដែលធ្លាប់មានបំណងរត់គេចចេញពីសហករណ៍មូលដ្ឋាន, ពួកអ្នកជម្លៀស១៧មេសា និងពួកខ្មែរក្រោមដែលត្រូវបានចោទថាជាពួកវៀតណាម[10] ។ ពួកអ្នកជាប់ឃុំទាំងនេះ ត្រូវស្ថិតនៅក្រោមការធ្វើទារុណកម្ម និងការសម្លាប់ចោល[11] ។

៦. ទួលម្ទេស គឺជាការដ្ឋានមួយនៅក្បែរនោះ ដែលមានមនុស្សជាច្រើនត្រូវបានស្ថិតនៅក្រោមការធ្វើពលកម្មដោយបង្ខំ, និងដែលត្រូវបានប្រើប្រាស់ធ្វើជាកន្លែងលត់ដំសម្រាប់ពួកកម្មាភិបាលតំបន់១ដែលត្រូវបោសសម្អាត[12] ។ ទំនប់ទឹក និងអាងទឹកដ៏ធំមួយ ត្រូវបានគេសាងសង់នៅកន្លែងនេះ[13] ។ ប្រជាជនដែលធ្វើការភាគច្រើន និងជនរងគ្រោះដទៃទៀតនៅក្នុងស្រុកនេះ គឺជាប្រជាជន១៧មេសា ដែលត្រូវបានជម្លៀសដោយបង្ខំមកពីផ្នែកផ្សេងៗនៃប្រទេស[14] ។

---

[8] បណ្តឹងរបស់ រឿង សុភាព (ROEUNG Sopheap), D230/1.1.671c ត្រង់លេខ ERN 00477557 [ដោយបានថ្លែងថា ប្តីរបស់គាត់ត្រូវបានចាប់ខ្លួននៅឯការដ្ឋានមួយកន្លែងនៅភូមិទួលម្ទេស និងត្រូវបានឃុំខ្លួននៅឯ "មន្ទីរសន្តិសុខ [sic] ភ្នំធិបតី" ] ។ បណ្តឹងរបស់ អាវ សុខចំរើន (AV Sok Chamroeun), D230/2/4.2.68b ត្រង់លេខ ERN 00503074 [ដោយបានថ្លែងថា កូនប្រុសរបស់គាត់ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅឯ "គុកភ្នំថ្គេ" ដែលមានទីតាំងនៅឯ "ភ្នំធិបតី"] ។

[9] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុក សុគន្ធា (OUK Sokunthea), D22/2543/1 ត្រង់លេខ ERN 00552316 ។

[10] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គឹម ផេង (KOEM Pheng), D22/2141/1 ត្រង់លេខ ERN 00546087-88 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ទី (CHEA Chanty), D22/3106/1 ត្រង់លេខ ERN 00561505 ។ បណ្តឹងរបស់ រឿង សុភាព (ROEUNG Sopheap), D230/1.1.671c ត្រង់លេខ ERN 00477557 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កឺ សឹង (KEU Seung), D22/2139/1 ត្រង់លេខ ERN 00546061 [ខ្មែរក្រោម] ។

[11] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ទី (CHEA Chanty), D22/3106/1 ត្រង់លេខ ERN 00561506 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កឺ សឹង (KEU Seung), D22/2139/1 ត្រង់លេខ ERN 00546061 ។

[12] បណ្តឹងរបស់ រឿង សុភាព (ROEUNG Sopheap), D230/1.1.671c ត្រង់លេខ ERN 00477557 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីរបស់ ហង់ បុរី (HANG Borey), D22/3882/1 ត្រង់លេខ ERN 00571582 [ដោយបានថ្លែងថា ដើមបណ្តឹងត្រូវបានគេ បញ្ជូនឱ្យទៅធ្វើការនៅ "ទំនប់ក្រហត នៅទួលម្ទេស"] ។ បទសម្ភាសន៍របស់ កសព លើឈ្មោះ នួន មួន (NOUN Moun), D1.3.11.36 ត្រង់លេខ ERN 00210532 [អតីតជំនួយការគណៈតំបន់១ ត្រូវបានគេបញ្ជូនទៅធ្វើការលត់ដំនៅទួលម្ទេស នៅក្រោមទំនប់កង្គត ផ្នែកខាង លិចភ្នំធិបតី"] ។ បញ្ជីឈ្មោះអ្នកទោសនៅស-២១ ដែលបានពិនិត្យឡើងវិញរបស់ កសព, D6.1.883 ត្រង់លេខ ERN 00330100 [ចុះបញ្ជី អ្នកទោសឈ្មោះ វ៉ែន វឿន (VAEN Voeun) ថាមកពីការដ្ឋានទួលម្ទេស ក្នុងតំបន់១] ។

[13] របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពីតំបន់១, ថ្ងៃទី២៨ ឧសភា ១៩៧៧, D1.3.10.2 ត្រង់លេខ ERN 00143568-69 [ដោយបានថ្លែងថា ប្រជាជនដែលធ្វើការនៅអាងទឹកធិបតី ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅទំនប់កង្គត និងនៅប្រព័ន្ធចែកចាយទឹកស្រែធិបតី] ។ សេចក្តីសង្ខេបព័ត៌មានបន្ថែមរបស់ កៅ ផារី (KAO Phary), D22/3221b ត្រង់លេខ ERN 00587278 [អ្នកដាក់ពាក្យបណ្តឹង "ត្រូវបានបង្ខំឱ្យកសាងទំនប់នៅភ្នំធិបតី"] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សឿង ចាន់ថន (SOEUNG Chanton), D22/3895/1 ត្រង់លេខ ERN 00571751 [អ្នកដាក់ពាក្យបណ្តឹងត្រូវបានគេចាត់តាំងឱ្យទៅដឹកប្រឡាយនៅឃុំធិបតី ក្នុងឆ្នាំ១៩៧៨] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហឺយ សាន (HAEY San), D22/3225/1 ត្រង់លេខ ERN 00562704 ។

[14] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យឹម ម៉ម (YIM Mam), D22/3765/1 ត្រង់លេខ ERN 00569789-90 [រៀបរាប់ពីការជម្លៀសប្រជាជនចំនួន ១៤.០០០ នាក់ ដោយបង្ខំឱ្យទៅកាន់ស្រុកគាស់ក្រឡ] ។ ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហ៊ុល

៧. បន្ទាប់ពីការមកដល់នៃពួកកម្មាភិបាលភូមិភាគនិរតី ក្នុងឆ្នាំ១៩៧៨ មានប្រជាជនជាច្រើនត្រូវបានចាប់ខ្លួន និងត្រូវបានសម្លាប់ចោល, វិន័យនៅតាមសហករណ៍នានាកាន់តែតឹងតែងឡើងៗ ហើយលក្ខខណ្ឌការងារកាន់តែធ្ងន់ធ្ងរទៅៗ[15] ។ នៅចុងឆ្នាំ១៩៨៧ ការសម្លាប់យ៉ាងរង្គាលទៅលើពួកអ្នកជាប់ឃុំ ពួកប្រជាជនដែលធ្វើការ និងពួកប្រជាជនដែលរស់នៅស្រុកគាស់ក្រឡ មានកើតឡើងនៅតាមទីកន្លែងផ្សេងៗ ទាំងក្នុង និងក្រៅស្រុកនោះ រួមមាន នៅភ្នំត្រជាក់ចិត្ត[16] និងនៅតំបន់អន្លង់វិលប្រែង (Anlong Vil Brèng Sector) (ភូមិឫស្សីព្រះ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ)[17] ។ ដូចមានសរសេរនៅក្នុងកថាខណ្ឌទី៩៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ជនសង្ស័យឈ្មោះ **យឹម ទិត** *ហៅ* **តាទិត** ត្រូវបានផ្លាស់ពីភូមិភាគនិរតី ទៅធ្វើជាលេខាតំបន់១ ក្នុងឆ្នាំ១៩៧៨ ។

៨. ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងស្រុកគាស់ក្រឡ រួមមាន ឧក្រិដ្ឋកម្មទាំងឡាយដូចបានរៀបរាប់នៅខាងលើ បានស្ថិតនៅក្រោមពាក្យបណ្ដឹងចំនួនជាង៤០ បណ្ដឹង ឬ ពាក្យសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនានាដែលបានដាក់នៅក្នុងសំណុំរឿងលេខ០០២[18] ។

---

ពៅ (HUL Peou), D22/140/1 ត្រង់លេខ ERN 00365322 [អ្នកដាក់ពាក្យបណ្ដឹង និងគ្រួសារត្រូវបានគេបញ្ជូនដោយរថយន្តធំៗជាមួយនឹងប្រជាជន ៧០០-៨០០ នាក់ ផ្សេងទៀត ពីខេត្តតាកែវទៅកាន់ភ្នំធិបតី ហើយបង្ខំឲ្យរែកដីសង់ទំនប់] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ មាស ណាគ្រី (MEAS Nakry), D22/117/1 ត្រង់លេខ ERN 00362159 [គ្រួសាររបស់អ្នកដាក់ពាក្យបណ្ដឹងត្រូវបានជម្លៀសដោយបង្ខំពីភ្នំពេញឲ្យទៅកាន់ភ្នំធិបតី ជាកន្លែងដែលគាត់បានឃើញពួកកម្មាភិបាល បកក ចាប់មនុស្សសម្លាប់ ហើយកប់នៅទំនប់ដែលគាត់បានធ្វើការ] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ គង់ វ៉ាច (KONG Vach), D22/131 ត្រង់លេខ ERN 00391744 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ ឈុំ វ៉ាន់នី (CHHUM Vanny), D22/2744/1 ត្រង់លេខ ERN 00556017-18 [ភាគច្រើននៃប្រជាជន ១.៣០០ នាក់នៅក្នុងសហករណ៍របស់គាត់នៅភ្នំធិបតី គឺមកពីភ្នំពេញ] ។

[15] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ សាង សៃ (SANG Say), D22/2743/1 ត្រង់លេខ ERN 00556006 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ ឈុំ វ៉ាន់នី (CHHUM Vanny), D22/2744/1 ត្រង់លេខ ERN 00556018 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហ៊ីយ សាន (HAEY San), D22/3225/1 ត្រង់លេខ ERN 00562704 [ដោយបានថ្លែងថា ការសម្លាប់កាន់តែច្រើនឡើងៗបន្ទាប់ពីពួកកម្មាលនិរតីបានកាន់កាប់កន្លែងធិបតី នៅដើមឆ្នាំ១៩៧៨] ។

[16] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា ចន្ទី (CHEA Chanty), D22/3106/1 ត្រង់លេខ ERN 00561506 [ដោយបានថ្លែងថាពួកខ្មែរក្រហមបានប្រមូលប្រជាជនពីភ្នំធិបតីដើម្បីសម្លាប់ចោលយ៉ាងរង្គាល] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណីរបស់ ផាន់ យឹម (PHANN Yim), D230/1.1.845c ត្រង់លេខ ERN 00481191 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យឹម ម៉ម (YIM Mam), D22/3765/1 ត្រង់លេខ ERN 00569790 ។

[17] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រី រ៉ង (RY Rang), D22/2909/1 ត្រង់លេខ ERN 00558413-14 [ដោយបានថ្លែងថា សមាជិកគ្រួសាររបស់គាត់ដែលនៅភូមិឫស្សីព្រះ ត្រូវបានបញ្ជូនទៅកាន់តំបន់អន្លង់វិលប្រែង (Anlong Vil Brèng Sector) ដើម្បីសម្លាប់ចោល នៅខែធ្នូ ឆ្នាំ១៩៧៨] ។

[18] *សូមមើលផងដែរ,* ព័ត៌មានបន្ថែមរបស់ ប៊ុត នឿន (BUT Noeun), D22/2912b ត្រង់លេខ ERN 00587239 [សមាជិកគ្រួសារត្រូវបានសម្លាប់នៅភ្នំធិបតី និងនៅភូមិទួលម្ទេស] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ បួយ ហួយ (BUOY Hauy), D22/1336/1 ត្រង់លេខ ERN 00526002 [ដោយបានថ្លែងថា ឪពុក ម្ដាយ និង បង-ប្អូនបង្កើតរបស់គាត់ ត្រូវបានសម្លាប់នៅក្បែរភ្នំធិបតីនៅគាស់ក្រឡ] ។ បណ្ដឹងរបស់ សាន វិសនា (SANN Visna), D230/2/3.1.971b ត្រង់លេខ ERN 00629083

## *១. មន្ទីរសន្តិសុខ តំបន់១*

៩. មន្ទីរសន្តិសុខ តំបន់១ គឺនៅក្នុងភូមិបាណន់ ឃុំកន្ទឺ (ដែលជាផ្នែកមួយនៃស្រុកសង្កែ ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ) បច្ចុប្បន្ន នៅត្រង់កន្លែងមន្ទីរស្រុកបាណន់[19] ។ វាធ្លាប់ត្រូវបានកំណត់អត្តសញ្ញាណដោយអតីតជំនួយការមួយរូបនៃគណៈតំបន់១ ដែលត្រូវបានចាប់ និងឃុំខ្លួននៅទីនោះ ដែលជាផ្នែកមួយនៃការបោសសម្អាតភូមិភាគពាយ័ព្យ[20] ។ មានប្រជាជនជាច្រើននាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅឯមន្ទីរសន្តិសុខនេះ ហើយនិងត្រូវបានយកទៅសម្លាប់ចោលនៅតាមទីកន្លែងផ្សេងៗ រួមមាន តំណាក់រាំង (Damnak Reang) នៅក្បែរប៉ៃលិន[21] ។

១០. ដូចបានកត់សម្គាល់នៅខាងលើ ជនសង្ស័យ ឈ្មោះ **យឹម ទិត** *ហៅ* **តាទិត** ធ្លាប់ធ្វើជាលេខាតំបន់១ នៃ បកក នៅភូមិភាគពាយ័ព្យ ក្នុងឆ្នាំ១៩៧៨ ។ តំបន់១ រួមមាន ស្រុកគាស់ក្រឡ ស្រុកសំឡូត ស្រុករតនៈមណ្ឌល (ហៅថា ស្រុកបាត់ដំបង ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ) និងស្រុកសង្កែ

---

[គ្រួសារត្រូវបានជម្លៀសពីភ្នំពេញទៅកាន់ភ្នំធិបតី ជា កន្លែងដែលឪពុក-ម្ដាយរបស់គាត់ត្រូវបានសម្លាប់] ។ បណ្ដឹងរបស់ ផូ សារេត (PHO Sereth), D230/2/3.1.983b ត្រង់លេខ ERN 00629087 [ការវាយតប់ ពលកម្ម ដោយបង្ខំ ការអត់ឃ្លាន ការរំលោភសេពសន្ថវៈ និងការសម្លាប់ នៅគាស់ក្រឡ] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ធុច ផាន់តារាស (THOUCH Phandarasar), D22/189/1 ត្រង់លេខ ERN 00279383, និងព័ត៌មានបន្ថែម, D22/189b ត្រង់លេខ ERN 00589320-21 [ដោយបានថ្លែងថា នៅក្រោយថ្ងៃទី១៧ មេសា ១៩៧៥ គ្រួសាររបស់នាងត្រូវបានបង្ខំឲ្យចេញពីភ្នំពេញទៅកាន់ភ្នំធិបតី ជាកន្លែងដែលសមាជិកភាគច្រើននៃគ្រួសាររបស់នាងបានស្លាប់] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជ័យ ធារ៉ា (CHEY Theara), D22/3033/1 ត្រង់លេខ ERN 00559155-56 ។ បណ្ដឹងរបស់ អ៊ុង សូយ (UONG Soy), D230/2/4.2.439b ត្រង់លេខ ERN 00622945-46 ។ បណ្ដឹងរបស់ ម៉ម យិន (MAM Yin), D230/2/3.1.16b ត្រង់លេខ ERN 00465039។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យឹម ម៉ម (YIM Mam), D22/3765/1 ត្រង់លេខ ERN 00569789-90 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ុម អេងហុង (SUM Eng Hong), D22/3755/1 ត្រង់លេខ ERN 00569682-83 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុន អែម (SON Em), D22/2896/1 ត្រង់លេខ ERN 00558226 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យុន សារឿន (YUN Saroeun), D22/505/1 ត្រង់លេខ ERN 00496627 ។

[19] បទសម្ភាសន៍របស់ កសព លើឈ្មោះ នួន មួន (NOUN Moun), D1.3.11.36 ត្រង់លេខ ERN 00210532 ។ បទសម្ភាសន៍របស់ កសព លើឈ្មោះ ធី ហន (THY Han), D1.3.11.55 ត្រង់លេខ ERN 00221580-81 [មន្ទីរសន្តិសុខតំបន់ នៅបាណន់ ខាងកើតស្ទឹងសង្កែ ក្បែរស្ពាន] ។

[20] បទសម្ភាសន៍របស់ កសព លើឈ្មោះ នួន មួន (NOUN Moun), D1.3.11.36 ត្រង់លេខ ERN 00210530, 00210532 ។

[21] បទសម្ភាសន៍របស់ កសព លើឈ្មោះ នួន មួន (NOUN Moun), D1.3.11.36 ត្រង់លេខ ERN 00210530, 00210532 ។ បទសម្ភាសន៍របស់ កសព លើឈ្មោះ ធី ហន (THY Han), D1.3.11.55 ត្រង់លេខ ERN 00221580 ។ បទសម្ភាសន៍ឈ្មោះ ហេង ទាវ (HENG Teav), D1.3.11.15 ត្រង់លេខ ERN 00426118-19 [ដោយបានរៀបរាប់ពីឧបទ្ទវហេតុដែលមានមនុស្សមួយក្រុមធំត្រូវបានចាប់ខ្លួន និងយកទៅដាក់នៅគុកបាណន់ តាមបញ្ជារបស់ ទិត លេខាតំបន់១ ហើយក្រោយមកត្រូវបានសម្លាប់ចោល] ។

(ដែលមានរួមបញ្ចូលនូវផ្នែកខាងកើតនៃស្រុកបាណន់ នាពេលបច្ចុប្បន្ននេះ, ដោយចាប់ផ្តើមនៅត្រង់ស្ទឹងសង្កែ)[22] ។

## *២. ការធ្វើទុក្ខបុកម្នេញ និង អំពើប្រល័យពូជសាសន៍លើពួកខ្មែរក្រោម*

១១. ជាផ្នែកមួយនៃគោលនយោបាយរបស់ខ្លួន ស្តីពីការលុបបំបាត់ពួកជនដែលមានសញ្ជាតិ ឬជាតិពន្ធុជាវៀតណាម និងពួកជនដែលមានជាប់ទាក់ទងជាមួយនឹងពួកវៀតណាម បកក បានផ្តោតគោលដៅទៅលើប្រជាជននៃកម្ពុជាប្រជាធិបតេយ្យដែលជាខ្មែរក្រោម រួមមាន ពួកខ្មែរក្រោមដែលរស់នៅក្នុងស្រុកគីរីវង់ ស្រុកត្រាំកក់ និង ស្រុកកោះអណ្តែត នៃខេត្តតាកែវ (ដែលជាផ្នែកមួយនៃតំបន់១៣ នៃភូមិភាគនិរតី) ហើយនិងនៅក្នុងស្រុកបាកាន នៃខេត្តពោធិ៍សាត់ (ដែលជាផ្នែកមួយនៃភូមិភាគពាយ័ព្យ) ។ ពួកប្រជាជនខ្មែរក្រោម ត្រូវបានគេស្គាល់ដោយសារសំនៀងសម្លេងរបស់ខ្លួន ក៏ដូចជានាមត្រកូលរបស់ខ្លួនដែលខុសប្លែកពីគេផងដែរ ដែលជាញឹកញាប់ ត្រូវបានគេកំណត់អត្តសញ្ញាណលើក្រុមជាតិពន្ធុរបស់ខ្លួន និងថាតើពួកគេមកពីទីកន្លែងណានៃកម្ពុជាក្រោម[23] ។

[22] ស្រុកទាំងឡាយនៅក្នុងតំបន់១ អាចត្រូវបានបញ្ជាក់ដោយកំណត់ត្រានានារបស់កម្ពុជាប្រជាធិបតេយ្យនាសម័យកាលនោះ និងចម្លើយសាក្សីផ្សេងៗ ។ *សូមមើល,* សៀវភៅកត់ត្រានៅស-២១, D6.1.963 ត្រង់លេខ ERN 00602557, 00602575 [កត់ត្រាអំពីតំបន់១ ថារួមមានស្រុកបាត់ដំបង ស្រុកសំឡូត ស្រុកសង្កែ និង ស្រុកគាស់ក្រឡ, ហើយស្រុកបាត់ដំបង មានរួមបញ្ចូលសហករណ៍ត្រែង ផ្លូវមាស និង ថ្មព្រះ (Treng, Phlov Meas and Thmar Prus cooperatives)] ។ របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពីតំបន់១, ថ្ងៃទី២៨ ឧសភា ១៩៧៧, D1.3.10.2 ត្រង់លេខ ERN 00143567-68 [របាយការណ៍ពីតំបន់១ រួមមានការពិភាក្សាអំពីស្រុកគាស់ក្រឡ ស្រុកសំឡូត និងស្រុកសង្កែ ហើយនិង ឃុំបាយដំរាំ] ។ របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពី ម-៥៦០, ថ្ងៃទី២៩ ឧសភា ១៩៧៧, D1.3.27.3 ត្រង់លេខ ERN 00183010-11 [យោងពីមន្ទីរតំបន់១ នៅក្នុងភូមិឈើទាល ហើយមន្ទីរស្រុកសង្កែ នៅក្បែរបាយដំរាំ] ។ បញ្ជីឈ្មោះអ្នកទោសនៅស-២១ ដែលបានពិនិត្យឡើងវិញរបស់ កសព, D6.1.883 ត្រង់លេខ ERN 00329603 [ចុះបញ្ជីអ្នកជាប់ឃុំឈ្មោះ ប៊ិន សោន (Bin Saun) ថាមកពីឈើទាល ស្រុកសង្កែ តំបន់១] និងលេខ ERN 00329941 [ចុះបញ្ជីឈ្មោះ ប្រាក់ សាវ៉ាត (Prak Savath) ថាជាយុទ្ធជនកងចល័តមកពីស្រុកគាស់ក្រឡ តំបន់១] ។ បទសម្ភាសន៍នៅខារអ៊ីដាង ថ្ងៃទី១៤, ១៩ វិច្ឆិកា ១៩៨០, D1.3.11.63 ត្រង់លេខ ERN 00217612 [បានយោងទៅដល់ "ស្រុកសង្កែនៅក្នុងតំបន់១ នៃភូមិភាគពាយ័ព្យ"] ។ បទសម្ភាសន៍នៅខារអ៊ីដាង ថ្ងៃទី២៤, ២០ វិច្ឆិកា ១៩៨០, D1.3.11.59 ត្រង់លេខ ERN 00217613 [បានយោងទៅដល់ "ស្រុកស្តៅនៅក្នុងតំបន់១ នៃភូមិភាគពាយ័ព្យ"] ។ កំណត់ហេតុនាំការស្តាប់ចម្លើយសាក្សីឈ្មោះ អ៊ុម សារឿន (UM Saroeun) របស់ កសចស, D6.1.173 ត្រង់លេខ ERN 00274618 [ដោយបានថ្លែងថា តំបន់១ បានលាតសន្ធឹងពីស្ទឹងសង្កែ ក្នុងស្រុកបាណន់ ទៅដល់ផ្លូវរទេះភ្លើង] ។ បទសម្ភាសន៍របស់ កសព លើឈ្មោះ អ៊ុក ស៊ីមន្ថា (UK Simontha), D1.3.11.58 ត្រង់លេខ ERN 00210561-62 [ដោយបានបញ្ជាក់ថា ឃុំបាយដំរាំ នៅក្នុងស្រុកបាណន់ សព្វថ្ងៃនេះ គឺជាផ្នែកមួយនៃតំបន់១ ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ] ។ បទសម្ភាសន៍របស់ កសព លើឈ្មោះ នួន មួន (NOUN Moun), D1.3.11.36 ត្រង់លេខ ERN 00210529 [មន្ទីរតំបន់១ នៅត្រង់កន្លែងប៉ុស្តិ៍នគរបាលរតនៈមណ្ឌល សព្វថ្ងៃ] ។

[23] ព័ត៌មានបន្ថែមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចៅ នី (CHAU Ny), D22/253a ត្រង់លេខ ERN 00596048 ។ បណ្តឹងរបស់ អ៊ុង សួយ (UONG Soy), D230/2/4.2.439b ។ Ben Kiernan, របប ប៉ុល ពត, D6.1.1106 ត្រង់លេខ ERN 00678651 ។

១២. ក្នុងឆ្នាំ១៩៧៦ និង១៩៧៧ ពួកមន្ត្រីខ្មែរ បកក នៅក្នុងស្រុកគីរីវង្ស បានធ្វើការសំរឹតសំរាំងប្រវត្តិរូបតាមគ្រួសារ និងកំណត់អត្តសញ្ញាណពួកខ្មែរក្រោម និងបានបើកធ្វើការសម្លាប់ជាទ្រង់ទ្រាយធំ[24] ។ ទីកន្លែងសម្លាប់នានាក្នុងស្រុកគីរីវង្ស គេបានយកពួកខ្មែរក្រោមទៅសម្លាប់ហើយ កប់នៅទីនោះ រួមមាន ព្រៃភូមិស្វែង[25] និងគុកវត្តសុបិន និងវត្តប្រធាតុ នៅក្នុងភូមគោកព្រិច[26] ។ រណ្តៅសពរួមនានាដែលខ្មែរក្រោមត្រូវបានយកទៅសម្លាប់ ត្រូវបានគេរកឃើញនៅវត្តអង្គុណ នៅក្នុងឃុំកំពែង និងនៅភូមិព្រេល និងភូមិសោម ដែលស្ថិតនៅក្នុងឃុំសោមដែរ[27] ។ ខ្មែរក្រោមត្រូវបានគេយកទៅដាក់គុកនៅវត្តសុបិន ដោយចោទថាក្បត់ ហើយត្រូវបានគេធ្វើទារុណកម្មរហូតដល់ពួកគេឆ្លើយសារភាព[28] ។

១៣. នៅក្នុងឧប្បត្តិហេតុមួយនោះ មានពួកទាហានដែលមកពីកម្ពុជាក្រោមប្រមាណជា៦០នាក់ដែលគេស្គាល់ថាជា"ពួកកន្សែងស" បានចូលមកភូមិត្រពាំងរុននៅក្នុងឃុំរាមអណ្តើក ស្រុកគីរីវង្ស និងបាននិយាយប្រាប់ពួកអ្នកភូមិនៅទីនោះថា ពួកខ្លួនមានបំណងចង់ជួបខៀវ សំផន[29]។ ពួកគេត្រូវបានពួកមន្ត្រីថ្នាក់ឃុំ និងសង្កាត់មកជួប ហើយនៅថ្ងៃបន្ទាប់មកពួកគេក៏ត្រូវបានគេដឹកតាមរថយន្តកាំមីញ៉ុងទៅកាន់មន្ទីរសន្តិសុខវត្តប្រធាតុ ហើយក៏ត្រូវគេសម្លាប់ចោល[30] ។ ដូចដែលបានលើកឡើងរួចមក

[24] ចម្លើយបន្ថែមពីលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ចៅ នី(CHAU Ny), ឯកសារលេខ D22/253a ត្រង់លេខ ERN 00596048។

[25] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ សាន់ ទូច (SANN Touch), ឯកសារលេខ D22/259 ត្រង់លេខ ERN 00426779-80។

[26] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ វ៉ែន ណាត (VEN Nat), ឯកសារលេខ D230/2/15 ត្រង់លេខ ERN 00426800 [ដែលរៀបរាប់អំពីការសម្លាប់ជាទ្រង់ទ្រាយធំនូវពួកទាហានកម្ពុជាក្រោមចំនួន៣៥នាក់ ដែលគេយកទៅកាន់វត្តសុបិន នៅក្នុងភូមិព្រៃជើង, និងការសម្លាប់អ្នកទោសចំនួន១២នាក់នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈ្មោះ ទុន សួន (TUN Soun), ឯកសារលេខ D22/258 ត្រង់លេខ ERN 00426759.

[27] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ម៉ៃ សុខន (MAY Sokhan), ឯកសារលេខ D22/262 ត្រង់លេខ ERN 00426836។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ សាន់ ទូច (SANN Touch), ឯកសារលេខ D22/259 ត្រង់លេខ ERN 00426780

[28] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ វ៉ែន ណាត(VEN Nat), ឯកសារលេខ D230/2/15 ត្រង់លេខ ERN 00426800។ *សូមអាន* កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទឹម ភួន (TIM Phuon)ដែលស្រង់ដោយ កសចស, ឯកសារលេខ D11 ត្រង់លេខ ERN 00698806 [ដែលនិយាយថា គាត់ត្រូវបានចាត់តាំងឱ្យធ្វើការនៅ "វត្តសុបិន" ដោយជនសង្ស័យឈ្មោះតាទិត]។

[29] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ទុន សួន (TUN Soun), ឯកសារលេខ D22/258 ត្រង់លេខ ERN 00426759 [ដែលនិយាយថា ព្រឹត្តការណ៍នោះបានកើតឡើងនៅដើមឆ្នាំ១៩៧៨]។ សៀវភៅរបស់លោក Ben Kiernan, ដែលមានចំណងជើងថា របប ប៉ុល ពត (*The Pol Pot Regime)*, ឯកសារលេខ D6.1.1106 ត្រង់លេខ ERN 00678495-96 [ដែលនិយាយថា ព្រឹត្តការណ៍នោះបានកើតឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៦]។

[30] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ទុន សួន (TUN Soun), ឯកសារលេខ D22/258 ត្រង់លេខ ERN 00426759 ។ សៀវភៅរបស់លោក Ben Kiernan, ដែលមានចំណងជើងថា របប ប៉ុល ពត (*The Pol Pot Regime)*, ឯកសារលេខ D6.1.1106 ត្រង់លេខ ERN 00678496។

ហើយនៅក្នុងកថាខណ្ឌទី៩៣នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ជនជាប់ចោទឈ្មោះ **យឹម ទិត** ហៅ **តា ទិត** គឺជាលេខា បកក នៃស្រុកគីរីវង្ស ចាប់តាំងពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ។

១៤. នៅក្នុងស្រុកត្រាំកក់ ដែលជាផ្នែករបស់តំបន់១៣នៃភូមិភាគនិរតីដែរនោះ ពួកប្រធានៗឃុំបានរៀបចំជាបញ្ជីឈ្មោះដើម្បីកំណត់អត្តសញ្ញាណពួកខ្មែរក្រោមដែលរស់នៅក្នុងតំបន់របស់ខ្លួន[31] ។ ជនជាប់ឃុំឃាំងដែលត្រូវបានសួរចម្លើយ និងធ្វើទារុណកម្មនៅមណ្ឌលសន្តិសុខក្រាំងតាចាន់ រួមមានខ្មែរក្រោមនិងប្រជាជន១៧មេសា អ្នកតាំងទីលំនៅថ្មីដែលមកពីស្រុកគីរីវង្ស[32] ។ របាយការណ៍នានារវាងមន្ទីរស្រុក មន្ទីរឃុំ និងមន្ទីរសន្តិសុខក្រាំង តាចាន់ដែលនិយាយពីរឿងការចាប់ខ្លួន ពួកខ្មែរក្រោម[33] ក៏ដូចជាជនខ្មែរក្រោមដែលកំពុងត្រូវបានគេនីរទេសឲ្យទៅកាន់ ឬដែលត្រូវគេយកទៅដោះដូរគ្នាជាមួយវៀតណាម[34] ។ ដោយស្រុកត្រាំកក់គ្មានព្រំប្រទល់ជាប់គ្នាជាមួយវៀតណាម ទេ

---

[31] *សូមអាន* ឧទាហរណ៍ដូចជា, ឯកសារលេខ D6.1.1232, D6.1.1214 (ឃុំអង្គតាសោម), ឯកសារលេខ D6.1.220 (ឃុំគូស), ឯកសារលេខ D108/26.293 ត្រង់លេខ ERN 00742626-28 (ឃុំពពេល), ឯកសារលេខ D6.1.470 (គូស), ឯកសារលេខ D6.1.1220 (អង្គតាសោម), ឯកសារលេខ D108/26.71 ត្រង់លេខ ERN 00763028-34 (ឃុំត្រពាំងធំខាងជើង)។

[32] ចម្លើយសារភាពនានាដែលស្រង់ដោយមន្ទីរសន្តិសុខក្រាំងតាចាន់, ឯកសារលេខ D6.1.217, ERN 00366676-98 ។ សៀវភៅរបស់លោក Ben Kiernan, ដែលមានចំណងជើងថា របបប៉ុលពត (*The Pol Pot Regime)*, ឯកសារលេខ D6.1.1106 ត្រង់លេខ ERN 00678590 [ចម្លើយសាក្សីថា នៅដើមឆ្នាំ១៩៧៧, ប្រជាជនថ្មីរាប់ពាន់នាក់នៅក្នុងស្រុកគីរីវង្សត្រូវបានគេបញ្ជូនឲ្យទៅកាន់ស្រុកត្រាំកក់ដើម្បីលត់ដំកែប្រែ ព្រោះបារម្ភថា ពួកគេមុខជានឹងលួចរត់គេចទៅប្រទេសវៀតណាម]។

[33] របាយការណ៍ពី ម៉េង ផ្ញើជូនអង្គការ, ចុះថ្ងៃទី១០ មករា ១៩៧៧, ឯកសារលេខ D6.1.235 ត្រង់លេខ ERN 00322122។ របាយការណ៍ពី មាន ជូនអង្គការ, ឯកសារលេខ D6.1.282 ត្រង់លេខ ERN 00366708 [ដែលបញ្ជាក់ពីការចាប់ខ្លួនគ្រាសារខ្មែរក្រោមបញ្ជូនទៅក្រាំងតាចាន់]។ របាយការណ៍ពីឃុំគូស (សែន) ជូនអង្គការ, ឯកសារលេខ D6.1.260 ត្រង់លេខ ERN 00369463-64។ របាយការណ៍ពីឃុំពពេល ផ្ញើជូនមន្ទីរស្រុកត្រាំកក់, ចុះថ្ងៃទី៣ ឧសភា ១៩៧៧, ឯកសារលេខ D6.1.234 ត្រង់លេខ ERN 00322121។ របាយការណ៍ពីឃុំពពេល (ជន) ផ្ញើជូនស្រុក១០៥, ចុះថ្ងៃទី៤ ឧសភា ១៩៧៧, ឯកសារលេខ D6.1.255 ត្រង់លេខ ERN 00322143។ របាយការណ៍ពីមន្ទីរស្រុក ផ្ញើជូនក្រាំងតាចាន់ (អាន់), ចុះថ្ងៃទី២៥ កញ្ញា ១៩៧៧, ឯកសារលេខ D6.1.262។ របាយការណ៍ពីជន, ចុះថ្ងៃទី៧ មីនា ១៩៧៨, ឯកសារលេខ D6.1.203 ត្រង់លេខ ERN 00322194-95 [ដែលរៀបរាប់អំពីការចាប់ខ្លួនខ្មែរក្រោមដែលមានការយល់ព្រមពីមន្ទីរស្រុក]។ របាយការណ៍ពីឃុំលាយបូរណ៍, ចុះថ្ងៃទី ២៩ មិថុនា ១៩៧៨, ឯកសារលេខ D6.1.207 ត្រង់លេខ ERN 00322216។ របាយការណ៍ពីឃុំពពេល ផ្ញើជូនមន្ទីរស្រុក, ចុះថ្ងៃទី១៣ កក្កដា ១៩៧៨, ឯកសារលេខ D6.1.209 ត្រង់លេខ ERN 00322219 [ការចាប់ខ្លួនខ្មែរក្រោមដែលមកពីពី "កងទ័ពកន្សែងស"]។

[34] របាយការណ៍ពីឃុំពពេល ផ្ញើជូនមន្ទីរស្រុកត្រាំកក់, ចុះថ្ងៃទី២ ឧសភា ១៩៧៧, ឯកសារលេខ, ឯកសារលេខ D6.1.1215 ត្រង់លេខ ERN 00276563-64 [ដែលរាយការណ៍ថា "ប្រជាជនកម្ពុជាក្រោម និងប្រជាជនយួនដែលត្រូវបានផ្ដោះប្ដូរជាមួយយើងឡើងចំនួនដល់៦៤គ្រួសារដែលមានចំនួនសរុបទាំងអស់២២៨នាក់"]។ របាយការណ៍ពីឃុំញ៉ែងញ៉ង ផ្ញើជូនមន្ទីរស្រុកត្រាំកក់, ចុះកាលបរិច្ឆេទខែឧសភា ឆ្នាំ១៩៧៧,ឯកសារលេខ D6.1.243 ត្រង់លេខ ERN 00322088 [ ដែលរាយការណ៍ថា "អនុលោមតាមសេចក្ដីសំរេចរបស់អង្គការ, យើងបានដឹកជញ្ជូនបងប្អូនកម្ពុជាក្រោម ដែលមានចំនួន៧នាក់ឲ្យវិលត្រឡប់ទៅប្រទេសរបស់យួនវិញ"]។ របាយការណ៍ពីឃុំតាផេន, ចុះថ្ងៃទិ១៣ ឧសភា ១៩៧៧, ឯកសារលេខ D6.1.1219 ត្រង់លេខ ERN 00290264 [ យោងការនីរទេសខ្មែរក្រោមពីឃុំសំរោង]។*សូមអានផង ដែរ* របាយការណ៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា *គំរោងដើម្បីជំរុញធ្វើឲ្យមានគណនេយ្យភាព៖ ទស្សនៈកិច្ចមួយ ទៅកាន់*

នោះ ទំនងដូចជា ជនណាដែលគេត្រូវបញ្ជូនឲ្យទៅកាន់ប្រទេសវៀតណាម ជាដំបូងគឺត្រូវ ឆ្លងកាត់តាមស្រុកគីរីវង្សសិន ។ ជាបន្ថែមពីលើមុខតំណែងជាលេខាស្រុក១គីរីវង្ស ជនជាប់ចោទ ឈ្មោះ **យឹម ទិត** *ហៅ* **តា ទិត** ក៏ជាសមាជិកហើយប្រហែលជាប្រធានគណៈកម្មាធិការតំបន់១៣ ផង[35] ។

១៥. នៅក្នុងស្រុកកោះអណ្តែត ការសម្លាប់ពួកខ្មែរក្រោមជាទ្រង់ទ្រាយធំ ត្រូវបានធ្វើឡើងនៅកន្លែងសម្លាប់ព្រៃសុខុន (ដែលគេស្គាល់ថា ព្រៃល្អាក់) ដែលស្ថិតនៅក្នុងភូមិស៊ីស្លា ឃុំផ្កាប្រជុំ[36] ។ ជនរងគ្រោះខ្មែរក្រោមនានាត្រូវបានគេឃុំឃាំងជាបណ្តោះអាសន្ននៅក្នុងវត្តអង្គសិរីមុនី និងបន្ទាប់មកទៀតត្រូវបានពួកកម្មាភិបាល បកក ប្រដាប់ដោយអាវុធ យកទៅសម្លាប់ទាំងក្រុម១ដែលម្តង១មានចំនួនពី១០ ទៅ ២០គ្រួសារ[37] ។ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី១០១ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ជនសង្ស័យឈ្មោះ **អ៊ឹម ចែម** គឺជាលេខា បកក នៃស្រុកកោះអណ្តែតចាប់ពីឆ្នាំ១៩៧៦ ដល់ ១៩៧៧ ។

១៦. នៅភូមិភាគពាយ័ព្យ ស្រុកបាកាន រួមមាន ភូមិមួយចំនួនដែលមានសុទ្ធតែប្រជាជនខ្មែរក្រោមច្រើនបំផុតរស់នៅ ដូចជាភូមិរំលិច (បន្ទាប់មកគេហៅថា ភូមិព្រៃឈើទាល) ក្នុងឃុំរំលិច និងភូមិបាក់មែក (បន្ទាប់មកគេហៅថាភូមិសេះញ៉ែវ) ក្នុងឃុំខ្នារទទឹង[38] ។ នៅក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានខ្មែរក្រមជាច្រើនត្រូវបានគេចាប់ខ្លួននិងឃុំខ្លួននៅតាមមន្ទីរសន្តិសុខនានា ក្នុងតំបន់នេះដែលរួមមាន គុកភូមិវាល (ដែលមានទីតាំងស្ថិតនៅក្នុងឃុំតាឡូ ស្រុកបាកាន)[39], គុកស្វាយជ្រុំ *ហៅ*

---

*ស្រុក ១០៩ , ភូមិភាគនីរតី* (*Project to Promote Accountability: A Visit to District 109, Southwestern Zone*), ចុះកាលបរិច្ឆេទខែកក្កដា ឆ្នាំ២០១០, ត្រង់លេខ ERN 00680851-52 [ ការធ្វើសម្ភាសន៍ទាហានខ្មែរក្រហមដែលនិយាយថា, នៅក្នុងឆ្នាំ១៩៧៧, បកក បញ្ជូនខ្មែរក្រោមទៅប្រទេសវៀតណាមជាថ្នូរនឹងការបញ្ជូនត្រឡប់នៃពួកខ្មែរដែលចុះចូល]។

[35] ចម្លើយរបស់ នុត នៅ (NUT Nouv) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.689 ត្រង់លេខ ERN 00422330។ ចម្លើយរបស់ ប៉ិច ជឹម (PECH Chim) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.650 ត្រង់លេខ ERN 00379169-70។ ចម្លើយរបស់ ទឹម ភួន (TIM Phuon) ការស្តាប់ចម្លើយសាក្សីធ្វើដោយមជ្ឈមណ្ឌល DC-Cam, ២២ មករា ២០១១, ត្រង់លេខ ERN 00644119 ។

[36] របាយការណ៍របស់ DC-Cam ស្តីពីការគូសប្លង់ផែនទីសំរាប់ខេត្តតាកែវ, ចុះកាលបរិច្ឆេទ ខែសីហា ឆ្នាំ១៩៩៨, ឯកសារ D1.3.10.14 ត្រង់លេខ ERN 00207679។

[37] របាយការណ៍របស់ DC-Cam ស្តីពីការគូសប្លង់ផែនទីសំរាប់ខេត្តតាកែវ, ចុះកាលបរិច្ឆេទ ខែសីហា ឆ្នាំ១៩៩៨, ឯកសារ D1.3.10.14 ត្រង់លេខ ERN 00207679។

[38] ចម្លើយរបស់ ថាច់ សុខ (THACH Sokh ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.140 ត្រង់លេខ ERN 00279241។ ព័ត៏មានបន្ថែមរបស់ គឹម សូ (KIM So), ឯកសារលេខ D22/102b ត្រង់លេខ ERN 00578021។

[39] ចម្លើយរបស់ ថាច់ សុខ (THACH Sokh ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.140 ត្រង់លេខ ERN 00279246 [មន្ទីរសន្តសុខនេះស្ថិតនៅភូមិព្រៃរៀងក្នុងឃុំតាឡូ, ប្រាំណជា៦ទៅ៧គីឡូម៉ែត្រពីភូមិរំលិច ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះគឹម សូ (KIM So),ឯកសារលេខ D22/102 ត្រង់លេខ ERN 00384366 [ ជនរងគ្រោះត្រូវបានចាប់ខ្លួន នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ និងត្រូវគេឃុំឃាំងនៅក្នុងមន្ទីឬសន្តិសុខភូមិវាល, ឃុំតាឡូ] ។ កំណាត់ហេតុចម្លើយរបស់ឈ្មោះគឹម សូ (KIM So) ដែលស្រង់ ដោយ កសចស, ឯកសារលេខ D6.1.759 ត្រង់លេខ ERN 00388620 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ចាប ខួង (CHAB Khuong), ឯកសារលេខ D22/103 ត្រង់លេខ ERN 00379339 [ជនរងគ្រោះត្រូវបានឃុំឃាំងនៅក្នុងគុកភូមិវាល ក្នុងឆ្នាំ១៩៧៦]។ ពាក្យសុំ

ភូមិថ្កោល និងបឹងបាតកណ្តាល *ហៅ* ត្រាចក្រោល (ដែលស្ថិតនៅក្នុងឃុំបឹងបាតកណ្តាល ស្រុកកាន[40]។ នៅតាមបណ្តាមន្ទីរសន្តិសុខទាំងនេះពួកខ្មែរក្រោមត្រូវគេធ្វើទារុណកម្ម សួរចម្លើយ ថាតើពួកគេគឺគេញរបស់វៀតណាម មែនឬមិនមែន ហើយត្រូវគេសម្លាប់ចោល[41] ។

១៧. នៅក្នុងឆ្នាំ១៩៧៨ ក្រោយពីការមកដល់តំបន់នេះរបស់ពួកម្ចាភិបាល បកក ដែលមកពីភូមិភាគនីរតី និងភូមិភាគបស្ចឹម ការសម្លាប់ខ្មែរក្រោមជាទ្រង់ទ្រាយធំបានកើតមានឡើងនៅក្នុងឃុំរំលិច និងឃុំខ្នារទទឹង[42] ។ ទីកន្លែងសម្លាប់ដែលជនរងគ្រោះទាំងនេះ ត្រូវបានគេសម្លាប់ និងកប់នោះ រួមមាន

---

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ធឿក យឿន (THOEUK Yoeun), ឯកសារលេខ D230/2/21 ត្រង់លេខ ERN 00427009-10។ បញ្ជីឈ្មោះមន្ទីរសន្តិសុខនានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកសារលេខ D6.1.525 ត្រង់លេខ ERN 00347411 [ដែលបង្ហាញពីអត្តសញ្ញាណរបស់គុកភូមិវាល នៅក្នុងស្រុកបាកាន] ។

[40] កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250740 [ ដែលរៀបរាប់អំពីគុកត្រាចក្រោល]។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ លឹម សាត ( LIM Sat) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.137 ត្រង់លេខ ERN 00250761 [ ដែលរៀបរាប់អំពីទីតាំងរបស់មន្ទីរសន្តិសុខថ្កោល (Thkaul security office), ដែលគេស្គាល់ឈ្មោះផងដែរថា មន្ទីរសន្តិសុខស្វាយជ្រុំ ឬមន្ទីរសន្តិសុខតាឃិន]។ បញ្ជីឈ្មោះមន្ទីរសន្តិសុខនានា របស់ មជ្ឈមណ្ឌលសន្តិសុខ, ឯកសារលេខ D6.1.525 ត្រង់លេខ ERN 00374411 [ដែលរៀបរាប់អំពីមន្ទីរសន្តិសុខបឹងបាតកណ្តាលក្នុងស្រុកបាកាន]។ នៅពេលខ្លះក្នុងឆ្នាំ១៩៧៨ ពួកអ្នកទោសដែលគេឃុំឃាំងនៅមន្ទីរសន្តិសុខថ្កោលត្រូវបានគេផ្ទេរបញ្ជូនទៅកាន់មន្ទីរសន្ទីរសន្តិសុខត្រាចក្រោល ។ កំណត់ហេតុចម្លើយសាក្សីរបស់ឈោះ លឹម សាត (LIM Sat) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.137 ត្រង់លេខ ERN 00250762 [សាក្សីត្រូវបានគេឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខថ្កោល ចាប់ពីឆ្នាំ១៩៧៦ ដល់១៩៧៨, បន្ទាប់មកទៀត ត្រូវបានគេបញ្ជូនរួមជាមួយពួកអ្នកទោសដទៃទៀត ឲ្យមកកាន់មន្ទីរសន្តិសុខត្រាច់ក្រោល]។

[41] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ គឹម សូ (KIM So),ឯកសារលេខ D22/102 ត្រង់លេខ ERN 00384366 [ជនរងគ្រោះត្រូវបានគេចោទថាជា "ពួកក្បាលយួនខ្លួនខ្មែរ" រៀបរាប់អំពីថា តើគាត់ត្រូវបានគេដាក់ខ្នោះ វាយដំនឹងដំបង និងដាក់ឲ្យខ្សែភ្លើងឆក់នៅក្នុងពេលសួរចម្លើយ, ហើយត្រូវបានគេបញ្ជាឲ្យជីករណ្តៅ និងកប់សាកសពពួកអ្នកទោសដែលគេបានសម្លាប់ចោលរបៀបដូចម្តេចខ្លះ?] ។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ គឹម សូ (KIM So) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.759 ត្រង់លេខ ERN 0038862 0។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ចាប ខួង (CHAB Khuong), ឯកសារលេខ D22/103 ត្រង់លេខ ERN 00379339-40 [ជនរងគ្រោះត្រូវបានគេដាក់ខ្នោះ, វាយដំ និងដាក់ឲ្យខ្សែភ្លើងឆក់នៅក្នុងពេលសួរចម្លើយនៅគុកភូមិវាល និងផ្តល់ចម្លើយជាសាក្សីអំពីមានការរំលោភសេពសន្ថវៈ និងសម្លាប់ពួកអ្នកទោសខ្មែរក្រោម នៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ធឿក យឿន (THOEUK Yoeun), ឯកសារលេខ D230/2/21 ត្រង់លេខ ERN 00427009-10 [អ្នកដែលនៅរស់ជីវិតពីគុកភូមិវាលបានរៀបរាប់ពីការសម្លាប់ពួកអ្នកទោសខ្មែរក្រោម] ។

[42] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ពៅ ស៊ីនួន (PEOU Sinuon), ឯកសារលេខ D22/101 ត្រង់លេខ ERN 00385226-27 [ដែលនិយាយថា មានខ្មែរក្រោមរាប់ពាន់នាក់ត្រូវបានគេប្រមូលដាក់ក្នុង "កន្លែងឃុំឃាំងនៅក្នុងក្រោលគោ" នៅក្នុងសហករណ៍នៅខ្នារទទឹង ក្នុងខែកក្កដា ឆ្នាំ១៩៧៨ ដោយពួកកម្មាភិបាល បកក មកពៅភូមិភាគនីរតី និងភូមិភាគបស្ចឹម ហើយត្រូវគេសម្លាប់នៅក្នុងព្រៃ១ក្រពៅ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ វឿន ដារា (VOERN Dara), ឯកសារលេខ D22/127 ត្រង់លេខ ERN 00398306-08 [ ខ្មែរក្រោមត្រូវបានគេប្រមូលដើម្បីយកទៅសម្លាប់នៅសហករណ៍ខ្នារទទឹង នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ គឹម សូ (KIM So), ឯកសារលេខ D22/102 ត្រង់លេខ ERN 00384366 [ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨, សាក្សីបានឮពួកកម្មាភិបាលនិយាយគ្នានៅគុកភូមិវាលថា "មានពួកខ្មែងយួនរាប់ពាន់នាក់" ត្រូវគេសម្លាប់ថ្មីៗនេះនៅសហករណ៍រំលិច និងខ្នារទទឹង]។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ជា ឡេង (CHEA Leng) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.142 ត្រង់លេខ ERN

រណ្ដៅសពទួលសេះញ៉ូវ[43] និងវាលពិឃាតព្រៃក្របៅ[44] ។ ការសម្លាប់ត្រូវបានធ្វើឡើងក្រោមការត្រួតពិនិត្យនិងបញ្ជារបស់លេខាស្រុកបាកានឈ្មោះ សេក សំអាត *ហៅ* យាយ រឹម[45] បន្ទាប់ពីយាយរឹម និងលេខាតំបន់ឈ្មោះ ព្រីង សារុន[46] បានធ្វើការ "ណែនាំឲ្យគ្រប់ប្រធានសហករណ៍ទាំងអស់នៅក្នុង

---

00279250។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ វ៉េន វ៉ាន (VEN Van), ឯកសារលេខ D22/267 ត្រង់លេខ ERN 00426924 [ ដែលបញ្ជាក់អំពីការសម្លាប់ខ្មែរក្រោមជាទ្រង់ទ្រាយធំ នៅក្នុងឆ្នាំ១៩៧៨ នៅព្រៃក្របៅ និងសេះញ៉ូវ]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ ធឿក ប៊ុនរឿន (THOEUK Bun Roeun), ឯកសារលេខ D230/2/17 ត្រង់លេខ ERN 00426904-05 ។ សៀវភៅរបស់លោក Ben Kiernan, ដែលមានចំណងជើងថា *របប ប៉ុល ពត* (*The Pol Pot Regime)*, ឯកសារលេខ D6.1.1106 ត្រង់លេខ ERN 00678651-52។

[43] កំណត់ហេតុចម្លើយសាក្សីឈ្មោះ ថាច់ សុខ (THACH Sokh) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.140 ត្រង់លេខ ERN 00279242 [ក្នុងឆ្នាំ១៩៧៩, សាក្សីបានឃើញរណ្ដៅនានាជាច្រើននៅក្នុងទំហំផ្ទៃដីពី៤០០ ទៅ៥០០ម៉ែត្រក្រឡា នៅទួលសេះញ៉ូវដែលក្នុងនោះមាន "សាកសពមនុស្សរាប់ពាន់នាក់" "ដែលគរលើគ្នា"]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ វឿន ដារា (VOERN Dara), ឯកសារលេខ D22/127 ត្រង់លេខ ERN 00398308 [គ្រួសារត្រូវគេសម្លាប់នៅទួលសេះញ៉ូវ]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ វ៉ាន់ ជោក (VAN Chauk), ឯកសារលេខ D22/271 ត្រង់លេខ ERN 00426975។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ សួង តឿ (SUONG Toeur), ឯកសារលេខ D230/2/16 ត្រង់លេខ ERN 00426887-88 [ បានផ្ដល់ចម្លើយជាសាក្សីអំពីពួកខ្មែរក្រហមយកខ្មែរក្រោមរាប់ពាន់នាក់ពីខាងទទឹងទៅកាន់ទួលសេះញ៉ូវនៅក្នុងខែកក្កដា ឆ្នាំ១៩៧៨] ។ ទីតាំងនេះ នៅជិតភូមិបាក់មែក (ដែលកាលពីក្នុងរបបខ្មែរក្រហមគេហៅថា សេះញ៉ូវ) ។

[44] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ ពៅ ស៊ីនួន (PEOU Sinuon), ឯកសារលេខ D22/101 ត្រង់លេខ ERN 00385227។ ព័ត៌មានបន្ថែមរបស់ឈ្មោះ គឹម សូ (KIM So), ឯកសារលេខ D22/102b ត្រង់លេខ ERN 00578027។

[45] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ ពៅ ស៊ីនួន (PEOU Sinuon), ឯកសារលេខ D22/101 ត្រង់លេខ ERN 00385227។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ ចាប ខួង (CHAB Khuong), ឯកសារលេខ D22/103 ត្រង់លេខ ERN 003793-40 ។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250740។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.991 ត្រង់លេខ ERN 00491349, 00491352-54។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ស៊ូ ណាន់ (SOU Năn) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.988 ត្រង់លេខ ERN 00508565 ។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ សេក សំអាត *ហៅ* រឹម (SEK Sâm At *alias* Rim) ដែលស្រង់ដោយ កសចស, ឯកសារលេខ, ឯកសារលេខ D6.1.984 ត្រង់លេខ ERN 00492920-21 [ ដែលទទួលស្គាល់ថា គាត់កាលណោះគឺជា សមាជិកគណៈកម្មាធិការស្រុកបាកានមួយរូប, ប៉ុន្តែបដិសេធថា គាត់មិនមែនជាលេខាទេ]។

[46] កំណត់ហេតុចម្លើយសាក្សីឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.991 ត្រង់លេខ ERN 00491349, 00491352-54។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ) ដែលស្រង់ដោយ SOAS/HRW ,ឯកសារលេខ D6.1.616 ត្រង់លេខ ERN 00352105-06។ កំណត់ហេតុចម្លើយរបស់ឈ្មោះ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច (KAING Guek Eav *alias* Duch) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.1052 ត្រង់លេខ ERN 00160720។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ស៊ូ ណាន់ (SOU Năn) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.988 ត្រង់លេខ ERN 00508565 -66។ កំណត់ហេតុចម្លើយរបស់ឈ្មោះ សេក សំអាត *ហៅ* រឹម (SEK Sâm At *alias* Rim) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.984 ត្រង់លេខ ERN 00492922។ សៀវភៅរបស់លោក Timothy Carney, ដែលមានចំណងជើងថា *អង្គការនៃអំណាច* (*The Organization of Power)* , ឯកសារលេខ D1.3.15.2 ត្រង់លេខ ERN 00105152។

ស្រុកបាកានប្រមូលប្រជាជនខ្មែរក្រោមរួចហើយ [ឲ្យយកពួកគេ] ទៅកាន់សហករណ៍ខ្នារទទឹង"[47] ។ ខ្មែរក្រោមត្រូវបាន បកក ចោទប្រកាន់ថា ជាពួក "ក្បាលយួនខ្លួនខ្មែរ" ហើយត្រូវបាន បកក សម្លាប់ចោលពីព្រោះពួកគេជាប់ពាក់ព័ន្ធជាមួយ "យួន"[48] ។ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី៩៥ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើទីបី ជនជាប់ចោទឈ្មោះ **យឹម ទិត** *ហៅ* **តា ទិត** ជាលេខា ឬអនុលេខាភូមិភាគពាយ័ព្យ នៅក្នុងពេលនៃការសម្លាប់ជាទ្រង់ទ្រាយធំទាំងនេះ[49] ។

*៣. ការសម្លាប់រង្គាលនៃប្រជាជនសម្លៀសមកពីភូមិភាគបូព៌ា (ភូមិភាគពាយ័ព្យ)*

១៨. ផ្នែកនេះមានបំណងបំភ្លឺ និងបំពេញបង្គ្រប់ចំពោះការអះអាងចោទប្រកាន់ទាក់ទិននឹងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ដែលមានចែងនៅក្នុងកថាខ័ណ្ឌទី៧៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ។

១៩. នៅចុងឆ្នាំ១៩៧៨ គឺក្នុងរយៈដ៏ខ្លីមុនការមកដល់របស់កងទ័ពវៀតណាម ប្រជាជនសម្លៀសមកពីភូមិភាគបូព៌ា ត្រូវបានគេប្រមូលផ្តុំនៅតាមកន្លែងមួយចំនួននៅក្នុងភូមិភាគពាយ័ព្យ និងបានសម្លាប់ចោលយ៉ាងរង្គាល[50] ។ ក្នុងឃុំស្រែស្តុក នៃស្រុកកណ្តៀង (ជាផ្នែកនៃតំបន់ ៧) ក្រោយពីមានការប្រជុំមួយ

---

[47] កំណត់ហេតុចម្លើយសាក្សីឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ), ឯកសារលេខ D6.1.991 ត្រង់លេខ ERN 00491353-54 [សក្ខីកម្មអំពីប្រធានសហករណ៍រំលិច]។

[48] កំណត់ហេតុចម្លើយសាក្សីឈ្មោះ ថាច់ សុខ (THACH Sokh) ដែលស្រង់ដោយ កសចស, ឯកសារលេខ 6.1.140 ត្រង់លេខ ERN 00279243។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ គឹម សូ (KIM So),ឯកសារលេខ D22/102 ត្រង់លេខ ERN 00384366 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ធឿក យឿន (THOEUK Yoeun), ឯកសារលេខ D230/2/21 ត្រង់លេខ ERN 00427009។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ វ៉េន វ៉ាន (VEN Van), ឯកសារលេខ D22/267 ត្រង់លេខ ERN 00426923។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ គឹម សូ (KIM So),ឯកសារលេខ D6.1.759 ត្រង់លេខ ERN 00388620។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ធឿក ប៊ុនរឿន (THOEUK Bun Roeun), ឯកសារលេខ D230/2/17 ត្រង់លេខ ERN 00426904 [ ដែលនិយាយថា ខ្មែរក្រោម" ត្រូវបានគេសម្លាប់ពីព្រោះខ្មែរក្រហមចាត់ទុកខ្មែរក្រោមថាជា ខ្មាំងយួន"] ។

[49] *សូមអានផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ធី ហាន (THY Han) ដែលស្រង់ដោយ កសចស, ឯកសារលេខ D20 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទីម ភួន (TIM Phuon) ដែលស្រង់ដោយ កសចស, ឯកសារលេខ D11 ។ កំណត់ធ្វើហេតុសម្ភាសន៍ឈ្មោះ ទឹម ភួន (TIM Phuon) ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, ចុះថ្ងៃទី ២២ មករា ២០១១, ERN 00644107-33 ។ របាយការណ៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា *គំរោងស្តីពីការជំរុញធ្វើឲ្យមានគណនេយ្យភាព៖ ឡេង អាន និង យឹម ទិត* (*Promoting Accountability Project: Leng Ann & Yim Tith)*, ចុះថ្ងៃទី ២២ មករា ២០១១, ERN 00៧0៤៥៨៣84 ។ រូបថត យឹម ទិត *ហៅ* តា ទិត ដែលថតដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា, ERN 00704582 ។ អត្ថបទកាសែត Phnom Penh Post, ដែលមានចំណងជើងថា *ចម្លើយសារភាពដែលត្រូវបានគេរំពឹងទុក នៅពេលដែលសវនាការ ឌុច ត្រូវបានចាប់ផ្តើមឡើងវិញបន្តទៀត (Confession expected as Duch trial resumes)*, ចុះថ្ងៃទី៣០ មីនា ២០០៩, ត្រង់លេខ ERN 00680839 ។

[50] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ ចក់ មល្លី, D6.1.143 ត្រង់ ERN 00288203-04; កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.643 ត្រង់ ERN 00373917 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នេត សាវឿន (NET Saveun), D22/3510/1 ត្រង់ ERN 00566485-86 [ជាប្រជាជនជម្លៀសពីភូមិភាគបូព៌ា រៀបរាប់អំពី

ជាមួយពួកកម្មាភិបាលសហករណ៍និងកម្មាភិបាលស្រុក គណៈសហករណ៍ផ្កាអំពិល (Phla Ampil) បានបញ្ជាឲ្យអង្គភាពរទេះគោ ដើម្បីដឹកអ្នកជម្លៀសពីភូមិភាគបូព៌ា ទៅ វាលបាក់ចិញ្ចៀនជាទីតាំងស្ថិតនៅចម្ងាយប្រហែល១០គីឡូម៉ែត្រ ភាគខាងលិចទួលពោធិ៍ជ្រៃ[51] ។ មនុស្សរាប់ពាន់នាក់ត្រូវបានគេដឹកទៅកាន់ទីតាំងនេះក្នុងរយៈពេលបីទៅបួនថ្ងៃ ដោយប្រើរទេះគោ៣០គ្រឿង[52] ។ ពេលមកដល់វាលបាក់ចិញ្ចៀន កងឈ្លប បកក បានបណ្ដើរជនរងគ្រោះទៅកាន់ស្រះទឹកមួយ ស្ថិតនៅចម្ងាយ១០០ម៉ែត្រ ហើយបាញ់សម្លាប់ពួកគេចោល[53] ។ បន្ទាប់មក សាកសពត្រូវបានទម្លាប់ទៅក្នុងស្រះនេះ[54] ។ លេខាស្រុកកណ្ដៀង(ស្រុក២២) នៅពេលមានការសម្លាប់មនុស្សយ៉ាងរង្គាលនាពេលនោះមានឈ្មោះថា ស៊ូ ណាន់ ជាប្អូន/បងស្រីរបស់ ស៊ូ ម៉េត ដែលបានបញ្ជូនចេញពីខេត្តកំពង់ឆ្នាំ មកកាន់ស្រុកនេះនៅចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨[55] ។

២០. នៅចុងឆ្នាំ១៩៧៨នេះដែរ ក្នុងឃុំរំចេក ស្រុកបាកាន មានអ្នកជម្លៀសមកពីភូមិភាគបូព៌ារាប់រយនាក់ក៏ត្រូវបានគេយកទៅវត្តច័ន្ទរង្សី ហើយបាញ់សម្លាប់ចោល[56] ។ នៅព្រឹកបន្ទាប់ សាកសពត្រូវគេដឹកម្ដងៗ៦នាក់ តាមរយៈគោ និងកប់ក្នុងរណ្ដៅកប់សាកសពរួម និងក្នុងអណ្ដូងមួយនៅភូមិកូនត្នោត ឬភូមិ

---

ការសម្លាប់រង្គាលនៅស្រុកបាកាន ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨]; ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឡឺ ហឿន, D22/264/1 ត្រង់ ERN 00426875-76 [បានឃើញមនុស្ស២០នាក់ មកពីស្វាយរៀង ត្រូវបានគេយកទៅសម្លាប់នៅឬស្សីក្រេង, ស្រុកមោងឫស្សី] ។

[51] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.145 ត្រង់ ERN 00284423; កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.643 ត្រង់ ERN 00373917 ។

[52] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.145 ត្រង់ ERN 00284423 ។

[53] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.145 ត្រង់ ERN 00284423 ។

[54] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.145 ត្រង់ ERN 00284423-24 ។

[55] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ អ៊ុង ឆាត់, D6.1.643 ត្រង់ ERN 00373918; កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស លើឈ្មោះ ស៊ូ ណាន់, D6.1.988 ត្រង់ ERN 00508563, 0050865-68 [សារភាពថា ខ្លួននាងត្រូវបានចាត់តាំងដោយលេខាតំបន់ឈ្មោះ ព្រីង សារុន (PRING Sarun) មកធ្វើគណៈស្រុកកណ្ដៀង ប៉ុន្តែអះអាងថា នាងមិនបានទទួលតំណែងនេះទេ] ។

[56] កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.991 ត្រង់លេខ ERN 00491351 [សក្ខីកម្មអំពីប្រធានសហករណ៍រំលិច។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250741 [ប្រធានឃុំរំលិច ចាប់ពីឆ្នាំ១៩៧៩ដល់៨៤ និយាយថាមានប្រជាជន៣០០នាក់ មកពីភូមិភាគបូព៌ាត្រូវបានគេបាញ់នៅវត្តរំលិច]។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ថាច់ សុខ (THACH Sokh) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.140 ត្រង់លេខ ERN 00279243។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ចក់មូលី (CHAK Muli) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.143 ត្រង់លេខ ERN 00288202-06 [ដែលរៀបរាប់អំពីតើពួកប្រជាជនជម្លៀសរាប់ពាន់នាក់ដែលមកពីភូមិភាគបូព៌ាត្រូវបានគេមកទទួលដឹកតាមរទេះគោពីស្ថានីយ៍រទេះភ្លើងបឹងខ្នារយកទៅឃុំរំលិច, និងក្រោយមកត្រូវបានគេប្រមូល និងសម្លាប់នៅក្នុងវត្តរំលិច តាមរបៀបដូចម្ដេចខ្លះ? ]។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ខឹម សាម៉ុន (KHOEM Samon) ដែលស្រង់ដោយ កសចស, ឯកសារលេខ D166/56 ត្រង់លេខ ERN 00327163-64 [សាក្សីដែលត្រូវបានគេជម្លៀសចេញពីភូមិភាគបូព៌ាទៅកាន់ខេត្តពោធិសាត់នៅចុងឆ្នាំ១៩៧៨ បាននិយាយថា មានពួកអ្នកជម្លៀសជាច្រើន ត្រូវបានគេ “បាញ់ស្លាប់” ហើយរៀបរាប់ពីការបានឃើញមានសាកសពជាច្រើននៅភូមិរំលិច]។

00728935



ចាម ក្នុងឃុំរំចេក[57] ។ ក្រមាពណ៌ខៀវ និងគ្រោងឆ្អឹងមនុស្សត្រូវបានគេរកឃើញនៅពេលជីករណ្តៅកប់សាកសពក្រោយឆ្នាំ១៩៧៩[58] ។ ចំនួនប៉ាន់ស្មាននៃជនរងគ្រោះដែលបានសម្លាប់នៅទីតាំងសម្លាប់មនុស្សនេះគឺចន្លោះពី៣០០ ទៅ៦៤០នាក់[59] ។ ដូចបានថែងពីខាងលើ លេខាស្រុកបាកាន (ស្រុក២១) នៅពេលមានការសម្លាប់មនុស្សយ៉ាងរង្គាលនាពេលនោះឈ្មោះ សេក សំអាត *ហៅ* យាយ រឹម (SEK Sâm At *alias* Rim) និងលេខាភូមិភាគពាយ័ព្យ គឺជនសង្ស័យ **យឹម ទិត *ហៅ* តា ទិត** ។

## ៤. ផែនការឧក្រិដ្ឋកម្មរួម[60]

២១. បទឧក្រិដ្ឋដូចបានរៀបរាប់ខាងលើ និងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រូវបានគេប្រព្រឹត្តឡើងក្នុងការជួយពន្លឿនបន្ថែមនៃផែនការឧក្រិដ្ឋកម្មរួម ឬ សហកម្មឧក្រិដ្ឋកម្មរួម របស់មេដឹកនាំជាន់ខ្ពស់ បកក ដើម្បីធ្វើឲ្យប្រជាជនក្លាយទៅជាទាសករ នៅតាមបណ្តាសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំនានា, ដើម្បីកំណត់អត្តសញ្ញាណ និងលុបបំបាត់ខ្មាំងរបស់ បកក តាមរយៈខ្សែបណ្តាញមន្ទីរសន្តិសុខ និងទីតាំងសម្លាប់នានា និងដើម្បីដាក់ចំណុចដៅទៅលើក្រុមសង្ស័យ ដូចជា ចាម និង វៀតណាម ដូចដែលបានរកឃើញដោយសហចៅក្រមស៊ើបអង្កេត ក្នុងកថាខ័ណ្ឌទី ១៥៦ ដល់២២០ នៃដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២[61] ។ សមាជិករបស់សហកម្មឧក្រិដ្ឋកម្មរួមនេះរួមមាន ប៉ុន្តែមានកំហិតតែត្រឹមប៉ុណ្ណឹងទេ សមាជិកនានារបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម បកក មេដឹកនាំក្រសួង និងលេខាភូមិភាគ តំបន់ និងកងពលធំយោធានៃមជ្ឈិមបក្ស[62] ។ ផែនការឧក្រិដ្ឋកម្មរួម ត្រូវបានគេអនុវត្តដោយបានដឹងជាមុនដោយមនុស្សជាច្រើន រួមមានលេខាស្រុករបស់

---

[57] កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.991 ត្រង់លេខ ERN 00491351។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250741 [ដែលបានផ្តល់សក្ខីកម្មជាសាក្សីអំពីការបានឃើញសាកសពមនុស្សជាច្រើននៅក្នុងរណ្តៅសពរួមចំនួនពីរ]។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ចក់ មូលី (CHAK Muli) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.143 ត្រង់លេខ ERN 00288206 ។ កំណត់ហេតុចម្លើយសាក្សីឈ្មោះ ថាច់ សុខ (THACH Sokh) ដែលស្រង់ដោយ កសចស, ឯកសារលេខ 6.1.140 ត្រង់លេខ ERN 00279243។

[58] កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250741។

[59] កំណត់ហេតុចម្លើយសាក្សីឈ្មោះ ចក់មូលី (CHAK Muli) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.143 ត្រង់លេខ ERN 00288206។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250741។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ ដួង សៅ (DUONG Sau) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.134 ត្រង់លេខ ERN 00250741។ កំណត់ហេតុចម្លើយសាក្សីរបស់ឈ្មោះ អ៊ុក សឿម *ហៅ* សន សឿម (UK Soeum *alias* Sân Soeum ) ដែលស្រង់ដោយ កសចស, ឯកសារលេខ D6.1.991 ត្រង់លេខ ERN 00491351។

[60] ផ្នែកនេះ គឺមានបំណងចង់បំពេញបង្គ្រប់ទៅលើការចោទប្រកាន់ទាំងឡាយនៅក្នុងកថាខណ្ឌទី១៦ និង១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣។

[61] ដីកាដំណោះស្រាយសំណុំរឿងលេខ ០០២, ១៥ កញ្ញា ២០១០, D427, កថាខ័ណ្ឌទី 156-220 ។

[62] ដីកាដំណោះស្រាយសំណុំរឿងលេខ ០០២, ១៥ កញ្ញា ២០១០, D427, កថាខ័ណ្ឌទី 159 ។

បកក និងប្រធានមន្ទីរសន្តិសុខ ដែលម្នាក់ៗក៏ជាសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួមស្ថិតនៅក្នុងស្រុក ឬមន្ទីរសន្តិសុខរបស់ពួកខ្លួន ។ បុគ្គលម្នាក់ៗទាំងនេះ តាមរយៈអំពើ និងការប្រព្រឹត្តរបស់ពួកគេ បាន រួមចំណែកធ្វើឲ្យសម្រេចបាននូវគោលដៅរួមនៃសហកម្មឧក្រិដ្ឋកម្មរួម និងដែលមានចេតនាចង់បាន លទ្ធផលទៅតាមនោះ ។

## ៥. ការកំណត់បទចោទខាងផ្លូវច្បាប់

២២. សហព្រះរាជអាជ្ញាមានមូលហេតុឲ្យជឿបានថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើ រួមបង្កើត បាននូវបទឧក្រិដ្ឋនានាដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការនេះ រួមមាន តែមិនកំហិតត្រឹម ប៉ុណ្ណឹងទេ ៖

i. អំពើប្រល័យពូជសាសន៍ចាម និង វៀតណាម ជាការរំលោភលើ **អនុសញ្ញាស្តីពីការបង្ការ និង ផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨**, ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា៤, មាត្រា២៩(ថ្មី) និង មាត្រា៣៩(ថ្មី) នៃ ច្បាប់ អ.វ.ត.ក ។

ii. មនុស្សឃាត និងទារុណកម្ម ជាការរំលោភ **ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦** (មាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ & ៥០៨), ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា ៣(ថ្មី), មាត្រា ២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃ ច្បាប់ អ.វ.ត.ក ។

iii. ការធ្វើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឲ្យទៅជាទាសករ, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការរំលោភសេពសន្ថវៈ, ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមបង្កើតបានជា **ឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិ**, ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា៥, មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃ ច្បាប់ អ.វ.ត.ក ។

iv. ការធ្វើមនុស្សឃាតដោយចេតនា, ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺ ចាប់ដល់រាងកាយ ឬសុខភាព, ការដកហូត ឬការបញ្ជូនដោយខុសច្បាប់ ឬការបង្ខាំងដោយ ខុសច្បាប់នៃជនស៊ីវិលណាម្នាក់ បង្កើតបានជា **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា ទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩**, ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា៦, មាត្រា២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃ ច្បាប់ អ.វ.ត.ក ។

២៣. សហព្រះរាជអាជ្ញាមានមូលហេតុឲ្យជឿបានថា យឹម ទិត ហៅ តា ទិត, ឱម អាន ហៅ តា អាន, អ៊ឹម ចែម និងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដទៃទៀត រួមទាំង នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ, បានប្រព្រឹត្តអំពើព្រហ្មទណ្ឌជាក់លាក់ ដូចបានរៀបរាប់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ជា

បទល្មើសមានចែងក្នុងច្បាប់ អ.វ.ត.ក ។ អំពើទាំងនេះគឺជាផ្នែកនៃផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួម ដូចមានចែងក្នុងកថាខណ្ឌទី១៨ នៃដីកាសន្និដ្ឋាននេះ និងកថាខណ្ឌទី១៦ ដល់១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ។

២៤. ឯកសារដែលបានលើកយោងក្នុងដីកាសន្និដ្ឋាននេះដែលជាឯកសារថ្មី ឬចេញពីសំណុំរឿងលេខ ០០២ ត្រូវបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ ១ ហើយសំណៅនៃច្បាប់ដែលលើកយោងត្រូវបានដាក់ភ្ជាប់ជាមួយជាឧបសម្ព័ន្ធ២ រហូតដល់៥៦ ។

២៥. ដីកាសន្និដ្ឋាននេះត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់គត់ អាស្រ័យហេតុដូចនេះ ដីកាសន្និដ្ឋាននេះ ត្រូវបានធ្វើឡើងតាមវិធាន៧១(៣) ។ ដោយអនុលោមតាមវិធាន ៧១(១) នៃវិធានផ្ទៃក្នុង កំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញានេះត្រូវបានដាក់ក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ដែលបានរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ។ ដោយហេតុថា រយៈពេលសាមសិប(៣០)ថ្ងៃ នៃការដោះស្រាយជម្លោះបានកន្លងផុតទៅហើយនោះ ទោះបីជាមានកិច្ចខំប្រឹងប្រែងជាបន្តបន្ទាប់យ៉ាងណាក្តី ក៏ការយល់ស្របគ្នាជាទូទៅមួយរវាងសហព្រះរាជអាជ្ញា មិនបានសម្រេចឡើយរហូតដល់ថ្ងៃនេះ ហើយគ្មានដំណើរការនីតិវិធីលើការខ្វែងយោបល់គ្នានេះ ត្រូវបានផ្តួចផ្តើមឡើងនៅចំពោះមុខអង្គជំនុំជម្រះទេ នោះសហព្រះរាជអាជ្ញាអន្តរជាតិ សូមដាក់ជូននៅទីនេះនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមជាទម្រង់ដើមរបស់វា ហើយនិងសូមស្នើដល់ សចស សូមឲ្យចាត់វិធានការធ្វើការស៊ើបសួរដូចដែលបានរៀបរាប់មកស្រាប់នៅក្នុងនេះជាបន្ទាន់ ។ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើដល់ សចស បន្ថែមទៀតថាសូមឲ្យចាត់ការលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះដោយកុំបង្អង់ ដោយស្របទៅនឹងគោលការណ៍ទូទៅនៃការសន្ទំថវិការបស់តុលាការ និងកាតព្វកិច្ចក្នុងការដឹកនាំដំណើរការនីតិវិធីឲ្យបានដល់ទីបញ្ចប់ នៅក្នុងរយៈពេលមួយដ៏សមស្រប[63] ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |

[63] វិធាន២១(៤) នៃវិធានផ្ទៃក្នុង ។